ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**************

សាលាឧទ្ធរណ៍ភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ៥៥៤ / ០៤.៦.២០១២

សាលដីកា

លេខ: ១០០ ក្រIIIសេ/ ២៥.១១.២០១៣

# តាងនាមប្រជារាស្ត្រខ្មែរ

# សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណ: នៅថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៣ ដោយមានសមាសភាពដូចតទៅ:

**<u>ក្រុមប្រឹក្សាជំនុំជម្រះ</u>**

លោក [redacted] ជាប្រធាន

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**<u>តំណាងមហាអយ្យការ</u>**

លោក [redacted]

**<u>ក្រឡាបញ្ជី</u>**

កញ្ញា [redacted]

ដើម្បីធ្វើការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ នៃសំណុំរឿងព្រហ្មទណ្ឌលេខ ៥៥៤ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១២ រវាង ៖

ជនជាប់ចោទឈ្មោ[redacted] ជា ភេទប្រុស អាយុ២០ឆ្នាំ ជាតិខ្មែរ កើតនៅ ភូមិតាកោម ឃុំតាកោម ស្រុកត្រាំកក់ ខេត្តតាកែវ ទីលំនៅមុនចាប់ខ្លួ[redacted] ខណ្ឌដង្កោ រាជធានីភ្នំពេញ ឪពុកឈ្មោ[redacted](រ) ម្តាយឈ្មោ[redacted] (រ) នៅលីវ ទោសពីមុនគ្មាន។

ចាប់ខ្លួនថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១១, ឃុំខ្លួនថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១១។

មានមេធាវីការពារលោក [redacted] វិបុល។

<u>ជាប់ចោទពីបទ:</u> លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា (គាស់សោទ្វារយក-សម្ភារៈក្នុងផ្ទះ) ប្រព្រឹត្តនៅ ផ្ទះលេខ២៦ ក្រុម៦ ផ្លូវបេតុង ភូមិព្រៃព្រីងខាងជើង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ .កាលពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោស តាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។៚



Scanned with CamScanner

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សេងលី ភេទប្រុស អាយុ៥៨ឆ្នាំ ជាតិខ្មែរ បច្ចុប្បន្នរស់នៅ ក្រុម៦ ភូមិព្រៃព្រីងខាងជើង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ។

## ដំណើររឿងមានដូចតទៅ៖

កាលពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១១ វេលាម៉ោង៨ និង៤០នាទីយប់ នៅចំណុចផ្ទះលេខ២៦ ក្រុម៦ ផ្លូវបេតុង ភូមិព្រៃព្រីងខាងជើង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ មានបទល្មើសមួយបានកើតឡើង ដែលបង្កដោយជនសង្ស័យឈ្មោះ [redacted] ជា បានធ្វើសកម្មភាពគាស់ទ្វារបន្ទប់ជួលរបស់ជនរងគ្រោះ ខណៈពេលដែលម្ចាស់បន្ទប់ជួលមិននៅ ដោយយកបានសម្ភារៈមួយចំនួនដូចជា កាបូបលុយ នាឡិកាដៃ។ ពេលកំពុងធ្វើសកម្មភាពក៏ត្រូវម្ចាស់ផ្ទះ រួមជាមួយអ្នកជិតខាងមកដល់ រួចឃាត់ខ្លួនជនសង្ស័យខាងលើប្រគល់ឲ្យសមត្ថកិច្ចតែម្តង។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ២៧ ក្រ៦ (ជ) ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១- ផ្តន្ទាទោសលើឈ្មោះ [redacted] ជា ភេទប្រុស អាយុ២០ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០៥ឆ្នាំ(ប្រាំឆ្នាំ) ពីបទលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហឹង្សា (គាស់សោទ្វារយកសម្ភារៈក្នុងផ្ទះ) ប្រព្រឹត្តនៅផ្ទះលេខ២៦ ក្រុម៦ ផ្លូវបេតុង ភូមិព្រៃព្រីងខាងជើង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

២- វត្ថុចាប់យកមានៈ

ក- ដង្កាប់ដ៏មួយ ទួឡីវីស ចំនួនមួយ រិបអូស និងបំផ្លាញចោល។

ខ- កាបូបដៃ១ នាឡិកាដៃចំនួន២ ខ្សែកលោហៈធាតុពណ៌លឿងចំនួនមួយខ្សែប្រវែង៤៣ ស.ម ប្រគល់ឲ្យម្ចាស់ដើមវិញ។

- សាលក្រមនេះ ជំនុំជម្រះ ថ្ងៃទី០២ ខែមីនា ឆ្នាំ២០១២ និងប្រកាសជាសាធារណៈ ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១២ ចំពោះមុខជនជាប់ចោទ កំបាំងមុខដើមបណ្តឹង។

បើកផ្លូវឲ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] ជា ជាជនជាប់ចោទប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ២៧ ក្រ៦ «ជ» ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ។



Scanned with CamScanner

បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

បានឃើញ របាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍ ។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សា បញ្ជាក់អង្គហេតុរឿងជូនអង្គសវនាការ

ក្រឡាបញ្ជីអានចម្លើយដើមបណ្តឹងឈ្មោះ [redacted] សេងលី ឆ្លើយនៅសាលាដំបូងរាជធានីភ្នំពេញ។

ជនជាប់ចោទឈ្មោះ [redacted]ដា ឆ្លើយថា ខ្លួនពិតជាបានគាស់ទ្វារបន្ទប់ផ្ទះគេមែន, សម្ភារៈសម្រាប់ប្រើគាស់ជារបស់ខ្លួន មានទួរឡឺវីស និងដង្កាប់ ដោយច្រលំថាជាផ្ទះសង្សារខ្លួន។ ពេលនោះខ្លួនយកបាននាឡិកា ០២គ្រឿង។ សំណូមពរ សុំសាលាឧទ្ធរណ៍បន្ធូរបន្ថយទោសដល់រូបខ្លួន។

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

បណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ យោងមាត្រា ៣៧៥ និង ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, យល់ឃើញថា មាភស្តុតាងដាក់បន្ទុកលើជនជាប់ចោទ ពីបទ —លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហឹង្សា មែន ដោយជនជាប់ចោទបានសារភាព ឃើញថាមានលក្ខណៈស៊ីសង្វាក់គ្នាទៅនឹងចម្លើយរបស់ដើមបណ្តឹង, យល់ឃើញថា សាលក្រមរបស់សាលាដំបូងសម្រេចត្រឹមត្រូវហើយ សូមសភាព្រហ្មទណ្ឌតម្កល់សាលក្រមរបស់សាលាដំបូងទុកជាបានការដដែល។

## សេចក្តីសន្និដ្ឋានរបស់មេធាវី

កូនក្តីខ្លួនឈ្មោះ [redacted]ដា ត្រូវបានសាលាដំបូងរាជធានីភ្នំពេញ សម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ៥ឆ្នាំ ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហឹង្សា ក្នុងសំណុំរឿងនេះ កូនក្តីខ្លួនបានប្តឹងឧទ្ធរណ៍ ហើយនៅក្នុងកំណត់ហេតុនៅសាលាដំបូង គឺគាត់សំណូមពរ សុំបន្ធូរបន្ថយទោសដល់រូបគាត់, ហើយកូនក្តីខ្លួនក៏បានទទួលស្គាល់ថាពិតជាបានលួចគាស់ទ្វារផ្ទះជួល គឺបន្ទប់លេខ០៩ របស់ឈ្មោ[redacted] សេងលី ពិតប្រាកដមែន ហើយការគាស់ គឺប្រើទួឡឺវីស ហើយចម្លើយប្រែប្រួល គឺថាគាត់មិនបានយកអីទេ តែនៅពេលដែលគាត់ឆ្លើយគឺ យកបាននាឡិកា២គ្រឿង មួយជារបស់គាត់ មួយជារបស់ម្ចាស់បន្ទប់, ដោយយល់ឃើញថាការផ្តន្ទាទោសតាមមាត្រា ៣៥៣, ៣៥៧ គឺស្ថិតនៅចន្លោះកម្រិតទោសពី ៣ ទៅ ១០ឆ្នាំ ហើយកូនក្តីខ្លួនត្រូវបានសាលាដំបូងសម្រេចដាក់ទោស៥ឆ្នាំ ខ្លួនយល់ឃើញថា វាមានលក្ខណៈធ្ងន់ធ្ងរបន្តិច ដោយសារព្យសនកម្មមានលក្ខណៈតិចតួច ហើយរបស់របរគឺត្រូវបានប្រគល់ឲ្យម្ចាស់ដើមវិញហើយ ដូច្នេះសូមលោកប្រធានក៏ដូចជាលោកលោកស្រីចៅក្រមប្រឹក្សាមេត្តាពិចារណាសម្រេចបន្ធូរបន្ថយទោសកូនក្តីខ្លួនត្រឹមកម្រិតអប្បបរមានៃទោស។

ដូចមានចែងក្នុងមាត្រា៣៥៧ និងមាត្រា៩៣ និង ៩៤ នៃក្រមព្រហ្មទណ្ឌ។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ,

ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី,

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី

ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់

**សាលាព្រហ្មទណ្ឌ**

**យល់ឃើញថា:**

១. បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] ដា ជាជនជាប់ចោទ ធ្វើក្នុងកំណត់ច្បាប់ តាមមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២. កាលពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១១ មានសកម្មភាពគាស់ទ្វារបន្ទប់យករបស់ទ្រព្យរបស់ជនរងគ្រោះ បានកើតឡើងនៅចំណុចផ្ទះលេខ២៦ ផ្លូវបេតុង ភូមិព្រៃព្រីងខាងជើង ប្រព្រឹត្តដោយឈ្មោ[redacted]ដា ហើយត្រូវម្ចាស់ផ្ទះគេមកទាន់ នៅពេលកំពុងធ្វើសកម្មភាព។

៣. តាមចម្លើយជនជាប់ចោទថា ខ្លួនពិតជាបានគាស់ទ្វារបន្ទប់ផ្ទះគេមែន, សម្ភារៈសម្រាប់ប្រើគាស់ជារបស់ខ្លួន មានទួរឡឺវីស និងដង្កាប់ ដោយច្រលំថាជាផ្ទះសង្សារខ្លួន។ ពេលនោះខ្លួនយកបាននាឡិកា២គ្រឿង។

៤. មានភស្តុតាងដាក់បន្ទុកលើជនជប់ចោទ ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហឹង្សា(គាស់សោទ្វារយកសម្ភារៈក្នុងផ្ទះ) ប្រព្រឹត្តនៅ ផ្ទះលេខ២៦ ក្រុម៦ ផ្លូវបេតុង ភូមិព្រៃព្រីងខាងជើង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១១ បទល្មើសមានចែង និងផ្តន្ទាទោសតាមមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៥. សាលក្រមព្រហ្មទណ្ឌលេខ ២៧ ក្រ៦ «ជ» ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចត្រឹមត្រូវ គួរតម្កល់ទុកជាបានការ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១. ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១២ របស់ឈ្មោះ[redacted]ដា ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។ ៦



Scanned with CamScanner

២. តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ២៧ ក្រ៦ «ជ» ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានី ភ្នំពេញទុកជាបានការ។

៣. បង្គាប់ឲ្យបន្តនូវការឃុំខ្លួនជនជាប់ចោទ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៣ ប្រកាសជាសាធារណៈ នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៣ ចំពោះមុខជនជាប់ចោទ, មេធាវីការពារជនជាប់ចោទ,

បើកផ្លូវសាទុក្ខ០១ខែ។

**សេចក្ដីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និង កងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។ល**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខ [redacted] | ហត្ថលេខា: [redacted], [redacted] | ហត្ថលេខា: [redacted] |

................................................................................................................................

បានឃើញ
ប្រធានសាលាឧទ្ធរណ៍
[redacted]

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ, ថ្ងៃទី ០៩ ខែ ..6. ឆ្នាំ ២០១៤
ក្រឡាបញ្ជី



Scanned with CamScanner